អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

NATIONAL AIDS AUTHORITY

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍

# កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង ៨:៣០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំប្រចាំខែក្រុមប្រឹក្សាបច្ចេកទេសក្រោមអធិបតីភាព**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ សមាសភាពចូលរួមនៅក្នុងកិច្ចប្រជុំនោះមានសមាជិក សមាជិកាថ្នាក់ដឹកនាំបច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធតាមរយៈប្រព័ន្ធអនឡាញ (Zoom) សរុបចំនួន ៣៦រូប។

**១-របៀបវារៈ÷**

- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។
- បទបង្ហាញស្តីពីវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ឆ្នាំ២០២៤ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បង្ហាញដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**២-ដំណើរការនៃកិច្ចប្រជុំ÷**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានធ្វើបទបង្ហាញពីវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ឆ្នាំ២០២៤៖

- តាមការប៉ាន់ប្រមាណតាមបែបវិទ្យាសាស្ត្រនៅឆ្នាំ២០២៣ មានអ្នកផ្ទុកមេរោគអេដស៍សរុបចំនួន ៧៦.០០០នាក់ ក្នុងនោះនៅត្រីមាសទី៣ ឆ្នាំ២០២៤ អ្នកមកទទួលសេវាថែទាំ និងព្យាបាលមានចំនួន ៦៨.៤១៣នាក់ និងប្រមាណ៧.០០០នាក់ មិនទាន់មកទទួលសេវាព្យាបាល។ ក្នុងនោះមានអត្រាប្រេវ៉ាឡង់ក្រុមស្ត្រីបម្រើសេវាកម្សាន្តសប្បាយមានចំនួន៤.៩% ឆ្នាំ២០២២ ក្រុមបុរសរួមភេទជាមួយបុរសមានចំនួន៥.៥% ឆ្នាំ២០២៣ ក្រុមបំប្លែងភេទមានចំនួន១៣.៥% ឆ្នាំ២០២៣ ក្រុមប្រើប្រាស់គ្រឿងញៀនមានចំនួន៥.៧% ឆ្នាំ២០១៧ និងដោយចាក់គ្រឿងញៀន មានចំនួន១៥.២% ឆ្នាំ២០១៧។
- អត្រាប្រេវ៉ាឡង់នៃអ្នកផ្ទុកមេរោគអេដស៍ បានថយចុះជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំមកនៅត្រឹម0,៥% ក្នុងចំណោមមនុស្សពេញវ័យអាយុពី១៥ ដល់៤៩ឆ្នាំ នៅឆ្នាំ២០២៣។
- នៅឆ្នាំ២០២៣ អ្នកឆ្លងថ្មីមានចំនួន១.២០០នាក់ ដែលតាមការវិភាគបានបង្ហាញថា ៨៦% ក្នុងចំណោមអ្នកឆ្លងថ្មីគឺជាប្រជាជនគន្លឹះ និងអតិថិជនរួមនឹងដៃគូដែលក្នុងនោះមាន ៤៦% ចំណោមបុរសរួមភេទជាមួយបុរស និងក្រុមអ្នកបំប្លែងភេទ១១% និងអ្នកស្លាប់មានចំនួន ១.១០០នាក់ (ថយចុះ២០០នាក់)។

• គោលដៅជាតិ៩៥-៩៥-៩៥ នៅឆ្នាំ២០២៣ កម្ពុជាសម្រេចបាន ៨៩% នៃអ្នកផ្ទុកមេរោគអេដស៍ បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ៩៨% នៃអ្នកផ្ទុកមេរោគអេដស៍ ដែលទទួលបានការព្យាបាល និង ៩៨% នៃអ្នកផ្ទុកមេរោគអេដស៍ ដែលបានទទួលការព្យាបាល ត្រូវពិនិត្យឃើញមានបន្ទុកមេរោគអេដស៍កម្រិតទាប។

ជាកិច្ចបន្ទាប់ **ឯកឧត្តមបណ្ឌិត** បានលើកបង្ហាញពីគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ ក្នុងចក្ខុវិស័យ៖ ធានាថា ប្រទេសកម្ពុជាជាប្រទេសមួយដែលគ្មានការគំរាមកំហែងពីមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងធានាថាប្រជាជនកម្ពុជាមានសុខភាពល្អ និងរស់នៅប្រកបដោយសុខុមាលភាព គ្មានការភ័យខ្លាចដោយសារជំងឺអេដស៍។ ក្នុងនោះ **ឯកឧត្តមបណ្ឌិត** បានលើកឡើងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០៥-២០២៨ លើកទី៦ ឈានទៅបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ និងដើម្បីសម្រេចបាននូវផែនការនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសេចក្តីសម្រេចស្តីពី ការកែសម្រួលក្រុមការងារដឹកនាំ និងតាមដានវឌ្ឍនភាពការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ ដែលមាន៤យុទ្ធសាស្ត្រ និងចែងចេញជា៥ក្រុមការងារ៖

១-ផ្តល់ការបង្ការ ព្យាបាល ថែទាំ និងគាំទ្រទូលំទូលាយ និងមានប្រសិទ្ធភាព តាមរយៈការសម្របសម្រួលល្អ និងប្រើប្រាស់វិធីសាស្ត្រជំរុញការចូលរួមជាពហុវិស័យ។

២-ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គម និងបង្កើតបរិយាកាសអំណោយផលឱ្យក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍បានទទួលសេវាមេរោគអេដស៍ សេវាសុខាភិបាល និងសេវាគាំទ្រ ផ្នែកច្បាប់ និងសង្គមផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។

៣-កសាងសមត្ថភាពស្ថាប័ន សហគមន៍ និងបុគ្គល ដើម្បីពង្រឹងការឆ្លើយតបដោយសហគមន៍ និងកែលម្អការធ្វើសមាហរណកម្មឆ្លើយតបនឹងមេរោគអេដស៍ក្នុងវិស័យសុខាភិបាល និងវិស័យមិនមែនសុខាភិបាល។

៤-ធានាចីរភាពសមិទ្ធផលជាតិនៃការឆ្លើយតបនឹងមេរោគអេដស៍ ដោយបង្កើនការវិនិយោគជាតិ និងការពង្រឹងប្រព័ន្ធប្រទេសឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈអភិបាលកិច្ចសម្របសម្រួល និងត្រួតពិនិត្យ។

៥-ត្រួតពិនិត្យ តាមដាន វាយតម្លៃវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ។

បន្ថែមពីនេះ **ឯកឧត្តមបណ្ឌិត** បានលើកឡើងនូវសេចក្តីសម្រេចចិត្តក្នុងកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៤ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ ដែលបានដាក់ចេញ៨ចំណុច រួមមាន៖

១-ចូលរួមអនុវត្តឱ្យបានជោគជ័យនូវគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា។

២-ទីស្តីការគណៈរដ្ឋមន្ត្រី និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍សម្របសម្រួលការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ឱ្យមាន ប្រសិទ្ធភាពខ្ពស់។

៣-ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវបង្កើនការផ្សព្វផ្សាយឱ្យយល់ដឹងអំពីហានិភ័យនៃមេរោគអេដស៍ ដល់ប្រជាជនទូទៅតាមវិស័យរៀងៗខ្លួន ដើម្បីប្រកាន់ខ្ជាប់នូវវិធានការបង្ការការឆ្លងរាលដាលមេរោគ អេដស៍ ជាពិសេសក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងព័ត៌មាន។

៤-គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវខិតខំស្វែងរកអ្នកសង្ស័យ ថាផ្ទុកមេរោគអេដស៍ប្រមាណជិត៧.០០០នាក់ ដែលមិនទាន់ដឹងពីស្ថានភាពមេរោគអេដស៍ និងទាក់ទាញ ពួកគេឱ្យមកធ្វើតេស្តរកមេរោគអេដស៍។

៥-ក្រសួងសុខាភិបាលបន្ត៖

–កាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យធ្លាក់ដល់កម្រិតតិចជាង៥ភាគរយ ដើម្បីសម្រេច បានគោលដៅលុបបំបាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

–ជំរុញបញ្ចូលសេវាថែទាំមេរោគអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាលទាំងស្រុង រួមមានការបង្កើនចំនួនទីតាំង ធ្វើតេស្ត និងធានាបានការព្យាបាលដល់គ្រប់អ្នកមានលទ្ធផលវិជ្ជមានមេរោគអេដស៍។

–ជំរុញមូលដ្ឋានសុខាភិបាលឯកជនឱ្យផ្តល់របាយការណ៍ស្តីពីការធ្វើតេស្ត និងព្យាបាលជំងឺអេដស៍ ដើម្បីដាក់បញ្ចូលព័ត៌មានក្នុងប្រព័ន្ធទិន្នន័យរបស់ក្រសួងសុខាភិបាល។

៦-ចំពោះអ្នកផ្ទុកមេរោគអេដស៍ដែលជាអនីតិជន ក្រសួងសុខាភិបាលត្រូវបង្កើនសេវា ថែទាំព្យាបាលជំងឺ អេដស៍ដល់កុមារផ្ទុកមេរោគអេដស៍ ដោយយកផលប្រយោជន៍របស់ពួកគេជាមូលដ្ឋាន។ ក្នុងករណី មានការព្រមព្រៀងពីអនីតិជន ហើយការធ្វើតេស្តរកមេរោគអេដស៍ផ្តល់អត្ថប្រយោជន៍ផ្ទាល់ចំពោះ អនីតិជន ក្រសួងសុខាភិបាលត្រូវណែនាំឱ្យអ្នកផ្តល់សេវាធ្វើតេស្តនោះ ធ្វើបានដោយពុំចាំបាច់មានការ យល់ព្រមពីអាណាព្យាបាលឡើយ។

៧-គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ប្រើប្រាស់កញ្ចប់ថវិកាជាតិសម្រាប់គណៈកម្មាធិការ អេដស៍រាជធានី ខេត្ត និងថវិកាដទៃទៀតក្នុងនោះ៖

– បង្កើត ឬធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយមានបញ្ចូលតំណាងអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ ក្នុងករណីចាំបាច់ឱ្យបានត្រឹម ត្រីមាសទីមួយឆ្នាំ២០២៥។

– សម្របសម្រួលអន្តរាគមន៍បង្ការ ពង្រឹងកម្មវិធីស្រោមអនាមន័យ ១០០% ការផ្តល់សេវាមេត្រីនៃ គ្លីនិកសុខភាពគ្រួសារបរិយាកាសគាំទ្រ និងការធ្វើតេស្តរកមេរោគអេដស៍ ផ្តោតលើប្រជាជនដែលមាន ហានិភ័យខ្ពស់ ជាអាទិ៍ក្រុមយុវវ័យបុរសរួមភេទជាមួយបុរស។

– ធ្វើឱ្យសម្រេចបានចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល ដល់ក្រុមប្រជាជនគន្លឹះឱ្យបាន ៥0% នៅដំណាច់ឆមាសទី១ ឆ្នាំ២០២៥ ដោយសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរទេសចរណ៍ បេឡាជាតិសន្តិសុខសង្គមសាខាខេត្ត ខណ្ឌ និងអាជ្ញាធរមានសមត្ថកិច្ច។

– បង្កើនសមត្ថភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ ឱ្យបានយល់ដឹង និង អនុវត្តគោលការណ៍បង្ការជាក់លាក់ (ចំប្រជាជនគោលដៅ ចំទីតាំងចំពេញវេលា ប្រើអន្តរាគមន៍ សមស្រប ប្រើប្រាស់ទិន្នន័យ និងប្រើធនធានវៃឆ្លាត) ដើម្បីរៀបចំផែនការសកម្មភាព និងវិភាជថវិកា សម្រាប់ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៨-អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំបង្កើតក្រុមការងារជានាចីរភាពដែលមានសមាសភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តន៍ផែនទីបង្ហាញផ្លូវចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍ ឆ្នាំ២០២៨ និងឆ្នាំ២០២៩។

**៣-ដាលទ្ធផលនៃកិច្ចប្រជុំ៖**

ជាកិច្ចបន្ត **ឯកឧត្តមបណ្ឌិត** ក៏បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួន ដែលត្រូវមានវិធានការណ៍ដោះស្រាយជាបន្តបន្ទាប់៖

- ក្រោយមានការឯកភាពរវាងក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការ UNAIDS និងរៀបចំទិន្នន័យរួមមួយ ដើម្បីយកទៅផ្សព្វផ្សាយជាផ្លូវការនៅឆ្នាំ២០២៥។
- ក្រុមប្រឹក្សាបច្ចេកទេសបន្តកិច្ចខិតខំប្រឹងប្រែងលើការងារ ដើម្បីឱ្យអត្រានៃការឆ្លងថ្មីនៅឆ្នាំ២០២៥ បន្តមានការធ្លាក់ចុះជាងឆ្នាំ២០២៤។
- ការឆ្លងថ្មី១.២០០នាក់ ឆ្នាំ២០២៤ ក្នុងចំណោមយុវវ័យដែលមានអាយុពី១៥-២៤ឆ្នាំ មាន៤៣% ដែលជាយុវជនស្ទួល និងត្រូវធ្វើយ៉ាងណាកាត់បន្ថយអត្រាឆ្លងថ្មីឱ្យនៅទាបបំផុតស្របនឹងគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលអាណត្តិទី៧នាពេលខាងមុខ តាមរយៈក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា បន្តផ្សព្វផ្សាយអេដស៍នៅក្នុងកម្មវិធីសិក្សាជាតិ។
- ការប្រើប្រាស់ស្រោមអនាម័យមានការធ្លាក់ចុះ ជាពិសេសក្រុមប្រជាជនគន្លឹះ មានត្រឹម ៦៨% ដោយពង្រឹងនិងពង្រីក តាមរយៈសេវាថែទាំ ព្យាបាល និងផ្សព្វផ្សាយក្នុងយន្តការដែលមានស្រាប់(សេចក្ដីសម្រេចលេខ:៣៧១ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤ ស្ដីពីការបង្កើតក្រុមការងារថ្នាក់ជាតិជំរុញការប្រើប្រាស់ស្រោមអនាម័យ១០០% ដើម្បីបង្ការមេរោគអេដស៍ និងជំងឺអេដស៍របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងលិខិតលេខ:៦៦ ស.ជ.ណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៩ ស្ដីពីវិធានការជំរុញប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០% របស់រាជរដ្ឋាភិបាលកម្ពុជា)។
- រាជធានីភ្នំពេញ បាត់ដំបង បន្ទាយមានជ័យ និងសៀមរាប ដែលមានការប្រឈមខ្លាំង ជាពិសេសក្រុមប្រជាជនគន្លឹះត្រូវបន្តកិច្ចខិតខំប្រឹងប្រែងបន្តអប់រំផ្សព្វផ្សាយឱ្យបានទូលំទូលាយពីមេរោគអេដស៍។
- យោងអនុក្រឹត្យលេខ១០៩ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលនៅសល់មិនទាន់បានបង្កើតត្រូវបន្តបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងលេខាធិការដ្ឋាន ប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ស្រុក ខណ្ឌ ឃុំ សង្កាត់ ឱ្យបានត្រឹមត្រីមាសទី១ ឆ្នាំ២០២៥ ដោយដាក់បញ្ចូលបន្ថែមសមាសភាពអ្នកតំណាងអ្នកផ្ទុកមេរោគអេដស៍ (ក្រុមMSM ក្រុមTG ក្រុមEW) មន្ទីរពេទ្យ មណ្ឌលសុខភាព អ្នកតំណាងប្រជាជនគន្លឹះ ទៅក្នុងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅក្នុងមូលដ្ឋានរបស់ខ្លួនផ្ទាល់។

ជាទីបញ្ចប់ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំ បានសម្ដែងនូវការកោតសរសើរដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងលេខាធិការដ្ឋានប្រយុទ្ធនឹង

ជំងឺអេដស៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គការនានា ដែលបានយកចិត្តទុកដាក់លើការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍កន្លងមក និងធ្វើឱ្យមានការផុសផុលក្នុងការផ្សព្វផ្សាយអេដស៍ ព្រមទាំងចូលរួមឆ្លើយតបនៅក្នុងបណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ ជាពិសេសតាមបណ្តាញសង្គម( FB, Tiktok... )ដោយឈរលើគោលការណ៍ឯកភាព និងជាវិជ្ជមាន។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង៣០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែលប្រកបដោយភាពស្និទ្ធស្នាល និងរីករាយ៕

ថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤

**បានឃើញ**
**ប្រធានអង្គប្រជុំ**

**បណ្ឌិត ឈឹម យិនដារ៉េត**

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រកពជនជាន**

**ហួត សេរីវឌ្ឍ**

**អ្នកធ្វើរបាយការណ៍**

**ស៊ុំ ផល្លា**